# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១១៥ សសរ

## សេចក្ដីសម្រេច
## ស្ដីពី
## ការបង្កើតគណៈកម្មការរៀបចំកិច្ចប្រជុំកំពូល
## គណៈកម្មការទន្លេមេគង្គលើកទី ៣

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្ដីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៩/៩៤៣ ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ២០០៩ ស្ដីពីការកែសម្រួល និងការធ្វើនិយតកាពការបង្កើតគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៩/១១៨១ ចុះថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ ២០០៩ ស្ដីពីការតែងតាំងសមាសភាពរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និងការកែសម្រួលឋានៈ របស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## សម្រេច

**ប្រការ ១.-**

បង្កើតគណៈកម្មការរៀបចំកិច្ចប្រជុំកំពូលគណៈកម្មការទន្លេមេគង្គលើកទី ៣ រួមមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **លឹម គានហោ** | រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា (គ.ជ.ទ.ម.ក) | ប្រធាន |
| ២- ឯកឧត្តម **ប៊ុន ហ៊ាន** | រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ទ.ម.ក | អនុប្រធាន |
| ៣- ឯកឧត្តម **លុយ ដាវីត** | រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៤- ឯកឧត្តម **ហោ សុភាព** | រដ្ឋលេខាធិការក្រសួងព័ត៌មាន | អនុប្រធាន |
| ៥- ឯកឧត្តម **សំរ៉ាង កំសាន្ត** | រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៦- ឯកឧត្តម **ម៉ៅ ហាវណ្ណាល់** | រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | អនុប្រធាន |

| | | |
|---|---|---|
| ៧- ឯកឧត្តម **អ៊ាង សុផល្លែត** | អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ៨- ឯកឧត្តម **វេស់ សីលវ៉ា** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៩- ឯកឧត្តម **ហ៊ាន ប៊ុនធឿរ** | អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១០- ឯកឧត្តមវេជ្ជបណ្ឌិត **សាន់ សាប់អី** | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ១១- ឯកឧត្តម **ហ៊ិន ស៊ីថា** | នាយករងខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី | សមាជិក |
| ១២- ឯកឧត្តមនាយឧត្តមសេនីយ៍ **នេត សាវឿន** | អគ្គស្នងការនគរបាលជាតិក្រសួងមហាផ្ទៃ | សមាជិក |
| ១៣- ឧត្តមសេនីយ៍ឯក **អន សុខុន** | មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១៤- ឯកឧត្តម **សៅ វណ្ណសិរីរិទ្ធ** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៥- ឯកឧត្តមបណ្ឌិត **ប៊ុនណារិទ្ធ** | អនុរដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១៦- ឯកឧត្តម **ឃឹម ប៊ុនសុង** | អភិបាលនៃគណៈអភិបាលខេត្តសៀមរាប | សមាជិក |
| ១៧- ឯកឧត្តម **តែ ណាវុធ** | អគ្គលេខាធិការ គ.ជ.ទ.ម.ក | សមាជិក |
| ១៨- ឯកឧត្តម **ចាន់ យុត្ថា** | នាយកខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ១៩- ឯកឧត្តម **ហ៊ែល តូនី** | អគ្គលេខាធិការ អាជ្ញាធរទន្លេសាប | សមាជិក |
| ២០- ឯកឧត្តម **ពេជ ឌុន** | ទីប្រឹក្សា គ.ជ.ទ.ម.ក | សមាជិក |
| ២១- ឯកឧត្តម **គល់ វឌ្ឍនា** | អគ្គលេខាធិការរង គ.ជ.ទ.ម.ក | សមាជិក |
| ២២- ឯកឧត្តម **វ៉ាត់ បុត្តកុសល** | អគ្គលេខាធិការរង គ.ជ.ទ.ម.ក | សមាជិក |
| ២៣- ឯកឧត្តម **សូ សុភ័ទ្ទ** | អគ្គលេខាធិការរង គ.ជ.ទ.ម.ក | សមាជិក |
| ២៤- ឯកឧត្តម **ឡុង សារាវុធ** | អគ្គលេខាធិការរង គ.ជ.ទ.ម.ក | សមាជិក |

**ប្រការ ២.-**

គណៈកម្មការរៀបចំកិច្ចប្រជុំកំពូលគណៈកម្មការទន្លេមេគង្គលើកទី ៣ មានភារកិច្ចដូចខាងក្រោម ៖

- រៀបចំកម្មវិធីប្រជុំ និងចាត់ចែងការងារពិធីការ ឲ្យបានសមស្រប
- សម្របសម្រួល និងរៀបចំការពារសន្តិសុខជូនគណៈប្រតិភូ ដែលអញ្ជើញចូលរួមកិច្ចប្រជុំ ឲ្យមានសុវត្ថិភាពល្អ
- សិក្សា ស្រាវជ្រាវ និងចងក្រងឯកសារសំខាន់ៗ សម្រាប់កិច្ចប្រជុំ
- សម្របសម្រួលជាមួយប្រព័ន្ធឃោសនាជាតិ និងអន្តរជាតិ ដើម្បីផ្សព្វផ្សាយព័ត៌មានជុំវិញការរៀបចំកិច្ចប្រជុំ
- រៀបចំមន្ទីរពេទ្យ គ្រូពេទ្យប្រចាំការ និងសង្គ្រោះបន្ទាន់ នៅតាមគោលដៅចាំបាច់
- ចាត់ចែងការសម្តែងសិល្បៈប្រពៃណី ជូនគណៈប្រតិភូក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ
- សម្របសម្រួល និងចាត់ចែងកិច្ចការទូទៅពាក់ព័ន្ធនឹងការរៀបចំកិច្ចប្រជុំឲ្យទទួលបានលទ្ធផលល្អប្រសើរ
- រៀបចំគម្រោងចំណាយសម្រាប់ការរៀបចំកិច្ចប្រជុំ ដើម្បីលើកសំណើសុំថវិកាពីរាជរដ្ឋាភិបាល
- សម្របសម្រួល និងសហការជាមួយលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ និងបណ្តាប្រទេសជាសមាជិក
- បំពេញការងារផ្សេងទៀត តាមការចាំបាច់ ។

**ប្រការ ៣.-**

ប្រធានគណៈកម្មការរៀបចំកិច្ចប្រជុំកំពូលគណៈកម្មការទន្លេមេគង្គលើកទី ៣ មានសិទ្ធិបង្កើតអនុគណៈកម្មការជំនាញផ្សេងទៀតតាមការចាំបាច់ ។

**ប្រការ ៤.-**

សមាសភាពគណៈកម្មការរៀបចំកិច្ចប្រជុំកំពូលគណៈកម្មការទន្លេមេគង្គលើកទី ៣ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល អភិបាលនៃគណៈអភិបាលខេត្តសៀមរាប រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធាន គ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃអង្គារ ៧ កើត ខែមិគសិរ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ